ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

*ថ្ងៃអង្គារ ៨រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៦*

# សេចក្ដីប្រកាសព័ត៌មាន

## គម្រោងវិនិយោគចំនួន៤៣ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ៧៥២លានដុល្លារអាម៉េរិក ត្រូវបានចុះបញ្ជីដោយគណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងខែមករា ឆ្នាំ២០២៦

ក្នុងខែមករា ឆ្នាំ២០២៦ គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានសម្រេចចុះបញ្ជីគម្រោងវិនិយោគសរុបចំនួន**៤៣គម្រោង** ក្នុងទំហំទុនវិនិយោគសរុបប្រមាណ**៧៥២លានដុល្លារអាម៉េរិក** និងអាចបង្កើតការងារបានប្រមាណ**២៦ពាន់កន្លែង**។ ក្នុងចំណោមគម្រោងវិនិយោគសរុប គម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ៣៥គម្រោង និងគម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ៨គម្រោង។ ក្នុងខែមករា ឆ្នាំ២០២៦ នេះ ការចុះបញ្ជីគម្រោងវិនិយោគមានការថយចុះចំនួន ២៥គម្រោង ស្មើនឹងប្រមាណ ៣៧% ខណៈទំហំទុនវិនិយោគមានការកើនឡើងប្រមាណ ៣,៤លានដុល្លារអាមេរិក ស្មើនឹងប្រមាណ ០,៤៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៥។ យ៉ាងណាមិញ ជាការកត់សម្គាល់ ក្នុងខែមករា ឆ្នាំ២០២៦ គណៈកម្មាធិការវិនិយោគកម្ពុជាបានចុះបញ្ជីគម្រោងវិនិយោគធំៗមួយចំនួនដូចជា គម្រោងវិនិយោគបង្កើតតំបន់សេដ្ឋកិច្ចពិសេសចំនួន ៣តំបន់ ក្នុងទំហំទុនវិនិយោគដល់ទៅ ២៦០លានដុល្លារអាម៉េរិក និងគម្រោងវិនិយោគអភិវឌ្ឍន៍ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព ១៥០មេហ្គាវ៉ាត់ ក្នុងទំហំទុនវិនិយោគប្រមាណ ២០០លានដុល្លារអាម៉េរិក។

គម្រោងវិនិយោគដែលមានភាពលេចធ្លោប្រចាំខែមករា ឆ្នាំ២០២៦ មានដូចខាងក្រោម៖

### ក. ក្រៅតំបន់សេដ្ឋកិច្ចពិសេស៖

| | |
|---|---|
| ហេដ្ឋារចនាសម្ព័ន្ធ | **គម្រោងវិនិយោគអភិវឌ្ឍន៍ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់**<br>- **ទីតាំង៖** ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី<br>- **ទំហំទុនវិនិយោគប្រមាណ៖** ២០០លានដុល្លារអាម៉េរិក<br>- **ការបង្កើតការងារ៖** ៤២កន្លែង។ |

**ឧស្សាហកម្ម**

**គម្រោងវិនិយោគបង្កើតរោងចក្រផលិតក្រណាត់គ្រប់ប្រភេទ**

- **ទីតាំង៖** ស្រុកកៀនស្វាយ ខេត្តកណ្ដាល
- **ទំហំទុនវិនិយោគប្រមាណ៖** ២៥លានដុល្លារអាម៉េរិក
- **ការបង្កើតការងារ៖** ១.៨២០កន្លែង។

**គម្រោងវិនិយោគបង្កើតរោងចក្រផលិតមី និងគ្រឿងផ្សំសម្រាប់មី**

- **ទីតាំង៖** ស្រុកគងពិសី ខេត្តកំពង់ស្ពឺ
- **ទំហំទុនវិនិយោគប្រមាណ៖** ២៣លានដុល្លារអាម៉េរិក
- **ការបង្កើតការងារ៖** ៨០៤កន្លែង។

**គម្រោងវិនិយោគបង្កើតរោងចក្រផលិតត្រីខកំប៉ុង និងទឹកត្រី**

- **ទីតាំង៖** ស្រុកដំណាក់ចង្អើរ ខេត្តកែប
- **ទំហំទុនវិនិយោគប្រមាណ៖** ៧លានដុល្លារអាម៉េរិក
- **ការបង្កើតការងារ៖** ១៧១កន្លែង។

## ខ. ក្នុងតំបន់សេដ្ឋកិច្ចពិសេស៖

**ហេដ្ឋារចនាសម្ព័ន្ធ**

**គម្រោងវិនិយោគបង្កើតតំបន់សេដ្ឋកិច្ចពិសេស កំពត ហ្វ៊ូជាន**

- **ទីតាំង៖** ស្រុកជុំគិរី ខេត្តកំពត
- **ទំហំទុនវិនិយោគ៖** ១២០លានដុល្លារអាម៉េរិក
- **ការបង្កើតការងារ៖** ២៣៧កន្លែង។

**គម្រោងវិនិយោគបង្កើតតំបន់សេដ្ឋកិច្ចពិសេស ខេភី យ៉ាញ**

- **ទីតាំង៖** ក្រុងបូកគោ ខេត្តកំពត
- **ទំហំទុនវិនិយោគ៖** ៦៥លានដុល្លារអាម៉េរិក
- **ការបង្កើតការងារ៖** ២៩១កន្លែង។

**គម្រោងវិនិយោគបង្កើតតំបន់សេដ្ឋកិច្ចពិសេស ភ្នំពេញ ឡូជីស្ទិក អេន អិនដាសស្ទៀល ខមផ្លេកស៍ (ខេមបូឌា ស៊ូភើផត)**

- **ទីតាំង៖** ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
- **ទំហំទុនវិនិយោគ៖** ៧៥លានដុល្លារអាម៉េរិក
- **ការបង្កើតការងារ៖** ៣៤០កន្លែង។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគក្នុង ខែមករា ឆ្នាំ២០២៦

ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការវិនិយោគកម្ពុជា
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គម្រោងវិនិយោគ**
**៤៣** (៨ គម្រោង ក្នុងតំបន់សេដ្ឋកិច្ចពិសេស)

**ទុនវិនិយោគ**
**៧៥១** លានដុល្លារអាមេរិក

**បង្កើតការងារ**
**~២៦ពាន់** កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាមេរិក)



**២៨៥ លាន** វិស័យឧស្សាហកម្ម

**៤៦៤ លាន** វិស័យហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ

**៣ លាន** កសិកម្ម និងកសិ-ឧស្សាហកម្ម

## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| 1. ចិន | ៣៥,៩០% |
| 2. ម៉ាឡេស៊ី | ២៦,៥៩% |
| 3. កម្ពុជា | ២៦,៥៧% |
| 4. សិង្ហបុរី | ៥,៩៨% |
| 5. កោះ British Virgin | ២,២៦% |
| 6. សីស្ហែល | ០,៩០% |
| 7. សាធារណរដ្ឋកូរ៉េ | ០,៧១% |
| 8. ជប៉ុន | ០,៦៨% |
| 9. សហរដ្ឋអាមេរិក | ០,៤០% |

## របាយគម្រោងវិនិយោគនៅតាមបណ្ដារាជធានី-ខេត្ត

